# <u>ការធ្វើរបាយការណ៍ ៩០ វិនាទី  នៅថ្ងៃព្រហស្បតិ៍  ទី១  ខែមិថុនា  ២០១៧</u>

## លោកស្រី  អូនៀល  (មណ្ឌល ហោតថាម) (១៣:៤៨ )

នាងខ្ញុំមានភ័ព្វសំណាង ដែលបានទទួលប្រតិភូសហគមន៍ខ្មែរ និងថ្នាក់ដឹកនាំសាសនាជាច្រើនអង្គ ដែលបានអញ្ជើញ និងនិមន្តមកកាន់រដ្ឋសភា កាលពីសប្តាហ៍កន្លងទៅ។ ពួកគេទាំងអស់ជាអ្នកតំណាងឲ្យពលរដ្ឋខ្មែរពី ៣០០០ ទៅ ៤០០០នាក់ និងប្រជាជនដែលនិយាយភាសាខ្មែរដែលនាងខ្ញុំតំណាងក្នុងមណ្ឌល **ហោតថាម**។

នាងខ្ញុំមានភ័ព្វសំណាងផងដែរ ដែលតំណាងឲ្យវត្តខ្មែរចំនួនបីក្នុងមណ្ឌល **ហោតថាម** មានដូចជា វត្តពុទ្ធរង្សី វត្តខ្មែរម៉ែលបិន និង វត្តធម្មារាម។ វត្តទាំងអស់នេះ ជានាព្រះសង្ឃមកធ្វើការបំរើកិច្ចការសាសនា និងរស់នៅក្នុងប្រទេសអូស្ត្រាលី។ ព្រះសង្ឃទាំងអស់ គឺជាបង្គោលដ៏ពិតប្រាកដក្នុងជីវភាពរស់នៅខាងផ្លូវចិត្ត និងសាសនា នៃប្រជាជនខ្មែរដែលនាងខ្ញុំតំណាង ។

ព្រះសង្ឃទាំងនោះដឹកនាំការបួងសួង និង ការគោរពបូជា និងរំលឹកធ្វើបុណ្យកំណើត ធ្វើបុណ្យសព ពិធីរៀបមង្គលការ ការឈឺស្កាត់ និងព្រឹត្តិការណ៍សំខាន់ផ្សេងៗ។

ការផ្លាស់ប្តូរច្បាប់អន្តោប្រវេសន៍មួយចំនួនដែលបានធ្វើឡើងកាលពីឆ្នាំ២០១៥កន្លងមក បច្ចុប្បន្ននេះតម្រូវឲ្យព្រះសង្ឃធ្វើដំណើរមកប្រទេសអូស្ត្រាលី ក្រោមកិច្ចសន្យាការងារពលកម្មទៅវិញ។

ច្បាប់ពីមុន អាចឲ្យព្រះសង្ឃធ្វើដំណើរ មកប្រទេសអូស្ត្រាលី ក្រោមទិដ្ឋាការជាអ្នកដឹកនាំសាសនា។ តាមច្បាប់ថ្មីនេះវាប្រៀបដូចព្យាយាមដាក់ស្នឹងដែលមានរាងបួនជ្រុង ទៅក្នុងរុនមូលអញ្ចឹង។ ឧទាហរណ៍ខ្លះៗ ដែលបញ្ជាក់ថាវាមានលក្ខណៈមិនត្រឹមត្រូវតាមច្បាប់ទាំងនេះ ដូចជាព្រះសង្ឃត្រូវតែមានកិច្ចសន្យាការងារពលកម្ម និងតម្រូវបង់ប្រាក់ខែឲ្យសមនឹងប្រាក់ខែ ដែលប្រជាជនក្នុងប្រទេសអូស្ត្រាលី ធ្វើការងារដូចគ្នា។ ក៏ប៉ុន្តែការតម្រូវ ឲ្យព្រះសង្ឃបង់ប្រាក់ខែនោះ វាគឺប្រឆាំងនឹងច្បាប់ព្រះពុទ្ធសាសនា ច្បាប់ថ្មីអនុញ្ញាតឲ្យវត្តអាចជានាព្រះសង្ឃបានតែមួយអង្គទេ តែតាមការពិត យើងត្រូវការព្រះសង្ឃជាច្រើនអង្គ ដើម្បីជាសេចក្តីត្រូវការ ក្នុងកម្មពិធីបុណ្យមួយក្នុងចំណោមពិធីបុណ្យដទៃទៀត។ ការតម្រូវឲ្យព្រះសង្ឃចេះភាសាអង់គ្លេសនោះ គឺជាបញ្ហាទៅហើយ ក៏ប៉ុន្តែគួរចងចាំថា ការបម្រើសេវាទាំងនេះ គឺប្រព្រឹត្តទៅក្នុងសហគមន៍ ដែលនិយាយតែភាសាខ្មែរសុទ្ធសាធ។

ដូច្នេះ នាងខ្ញុំសូមស្នើដល់រដ្ឋមន្ត្រីអន្តោប្រវេសន៍ និងការពារព្រំដែន ពិចារណាឡើងវិញ ដោយការគួរនូវសេចក្តីត្រូវការដ៏សំខាន់ទាំងនេះ ជូនដល់ពលរដ្ឋខ្មែរអូស្ត្រាលីដើម្បីធ្វើឲ្យប្រាកដថា ព្រះសង្ឃអាចបន្តផ្តល់នូវសេវាសំខាន់និងការថែរក្សានេះ ដល់សហគមន៍ ដែលនាងខ្ញុំតំណាង។

## 90 Second Statement – Thursday 1 June 2017

### Ms O'NEIL (Hotham) (13:48):

I was very lucky to welcome a delegation of Cambodian community and religious leaders to parliament earlier this week. They represent some of the 3,000 or 4,000 Cambodian and Khmer speaking people I represent in Hotham. I am also lucky to represent three Cambodian Buddhist temples in Hotham—the Watt Buddharangsi, the Khmer Buddhist Centre and the Dhamaram Buddhist Temple. All these three temples sponsor Cambodian Buddhist monks to come and live in Australia. Those monks are absolutely core to the religious and spiritual life of the Cambodian people that I represent. They lead prayer and worship, and they commemorate births, deaths, marriages, illness and other critical life events.

Immigration changes that were made in 2015 now require monks to travel to Australia under a labour agreement scheme. Previously, they were able to come under a specified religious leaders visa. Under this new scheme it is like trying to fit a square peg into a round hole. Some examples of why this is not a good fit: under these laws the monks must be shown to have a labour agreement and be paid commensurate with people in Australia who are doing similar work, yet that sort of payment is against Buddhist teachings; only one monk per temple can be sponsored, when in fact we need multiple monks at each of these ceremonies; and language requirements are a problem, remembering that these services a mainly Khmer speaking community.

So I would like to ask the Minister for Immigration and Border Protection to consider the special needs of Cambodian Australians so we can ensure that Buddhist monks can continue to provide this critical service and care to the community I represent.